# ធម្មរុចិត្ថេរាបទាន

## (រឿងមេឃតាបសជាមិត្ររបស់សុមេធបណ្ឌិត)




*កាលណា ព្រះជិនសិរីសម្ពុទ្ធជាម្ចាស់ ព្រះនាមទីបង្ករ: ទ្រង់ព្យាករនូវព្រះសុមេធតាបសថា សុមេធតាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងអបរិមេយ្យកប្ប (កប្បរាប់មិនបាន) អំពីកប្បនេះ ។*

*ព្រះមាតាបង្កើតនៃព្រះពុទ្ធនេះព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទន: សុមេធតាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធព្រះនាមគោតម: ។*

*សុមេធតាបសនេះ តម្កល់ទុកនូវសេចក្តីព្យាយាមហើយ ធ្វើនូវទុក្ករកិរិយា នឹងបានត្រាស់ដឹងជាព្រះសម្ពុទ្ធ មានយសធំ ក្រោមម្លប់នៃអស្សត្ថព្រឹក្ស ។*

*ភិក្ខុឈ្មោះឧបតិស្ស: ១ ឈ្មោះកោលិត: ១ នឹងបានជាសាវ័កដ៏ប្រសើរ ភិក្ខុជាអ្នកឧបដ្ឋាកមាននាមថា អានន្ទ នឹងបម្រើនូវព្រះជិនស្រីអង្គនេះ ។*

## (រឿងមេឃតាបសជាមិត្ររបស់សុមេធបណ្ឌិត)

ភិក្ខុនីឈ្មោះខេមា ១ ឈ្មោះឧប្បលវណ្ណា ១ នឹងបានជាសាវិកាដ៏ប្រសើរ គហបតីឈ្មោះចិត្តៈ ១ ឈ្មោះអាឡវកៈ ១ នឹងបានជាឧបាសកដ៏ប្រសើរ ។

នាងខុជ្ជុត្តរា ១ នាងនន្ទមាតា ១ នឹងបានជាឧបាសិកាដ៏ប្រសើរ ដើមឈើសម្រាប់ត្រាស់ដឹងនៃអ្នកប្រាជ្ញអង្គនេះ គេហៅថា អស្សត្ថព្រឹក្ស ។

ពួកមនុស្សនិងទេវតា បានឮព្រះពុទ្ធដីកានេះ នៃព្រះពុទ្ធជាបុគ្គលស្វែងរកនូវគុណដ៏ធំ ឥតមានបុគ្គលណាស្មើ ក៏មានចិត្តរីករាយ នាំគ្នាធ្វើអញ្ជលីនមស្ការ ។

បពិត្រព្រះមហាមុនី កាលនោះ ខ្ញុំជាមាណព ឈ្មោះមេឃ អ្នកសិក្សាប្រពៃ បានឮពាក្យព្យាករណ៍ដ៏ប្រសើរ នៃសុមេធតាបស ។

ខ្ញុំស្និទ្ធស្នាលនឹងសុមេធតាបស មានករុណាជាលំនៅ ខ្ញុំក៏បានបួសតាមតាបស ជាអ្នកមានព្យាយាម ដែលទ្រង់ផ្នួសនោះ ។

ខ្ញុំសង្រួមក្នុងបាដិមោក្ខផង ក្នុងឥន្ទ្រិយទាំង ៥ ផង មានអាជីវៈដ៏បរិសុទ្ធ មានសតិ ជាអ្នកប្រាជ្ញ ជាអ្នកធ្វើតាមពាក្យប្រៀបប្រដៅរបស់ព្រះជិនស្រី ។

កាលខ្ញុំនោះជាមួយបាបមិត្រណាមួយ ក៏បានប្រកបក្នុងអនាចារហើយ ឃ្លាតចាកផ្លូវដ៏ល្អ ។

ខ្ញុំជាអ្នកលុះក្នុងអំណាចវិតក្កៈ បានចៀសចេញអំពីសាសនា វេលាក្រោយមក ខ្ញុំបានប្រកបដោយបាបមិត្តអាក្រក់នោះទៀត ក៏ប្រព្រឹត្តធ្វើនូវមាតុឃាត ។

ខ្ញុំមានចិត្តប្រទូស្ត បានធ្វើអនន្តរិយកម្ម គឺសម្លាប់មាតា ខ្ញុំច្យុតអំពីអត្តភាពនោះ បានទៅកើតក្នុងមហាអវីចិនរក ក៏អាក្រក់ក្រៃពេក ។

ខ្ញុំទៅកើតក្នុងអសុរកាយ ដល់នូវសេចក្តីទុក្ខ អន្ទោលទៅអស់កាលជាយូរអង្វែង លែងបានឃើញព្រះសុមេធតាបស ជាអ្នកប្រាជ្ញប្រសើរជាងជន ។

## (រឿងមេឃតាបសជាមិត្ររបស់សុមេធបណ្ឌិត)

ក្នុងកប្បនេះ ខ្ញុំបានកើតជាត្រីសមុទ្រ ឈ្មោះតិមិង្គលៈ បានឃើញសំពៅក្នុងសាគរ ក៏ចូលទៅជិតដើម្បីអាហារ ។

ពាណិជទាំងឡាយ បានឃើញខ្ញុំហើយ ក៏មានសេចក្តីភិតភ័យ បាននាំគ្នារំលឹកគុណនៃព្រះពុទ្ធដ៏ប្រសើរ ថាគោតមៈៗ ដូច្នេះ ខ្ញុំក៏បានឮសំឡេងគឹកកងខ្លាំង ដែលពួកពាណិជទាំងនោះពោលហើយ ។

ខ្ញុំរលឹកឃើញនូវសញ្ញាអំពីដើម តអំពីនោះមក ខ្ញុំធ្វើនូវមរណកាល បានទៅកើតក្នុងកំណើតនៃព្រាហ្មណ៍ ជាត្រកូលស្តុកស្តម្ភ ក្នុងក្រុងសាវត្ថី ។

ខ្ញុំមានឈ្មោះ ធម្មរុចិ ជាអ្នកខ្ពើមរអើមនូវបាបទាំងពួង មានអាយុ ៧ ឆ្នាំរាប់អំពីកំណើត បានឃើញព្រះពុទ្ធជាពន្លឺក្នុងលោក ។

ខ្ញុំបានទៅកាន់វត្តជេតពនដ៏ប្រសើរ ហើយចូលកាន់ផ្នួស ចូលទៅជិតព្រះពុទ្ធ អស់វារៈ ៣ ដង រាល់យប់រាល់ថ្ងៃ ។

កាលនោះ ព្រះមុនីបានទតឃើញខ្ញុំហើយ ក៏ត្រាស់ថា នែធម្មរុចិ អ្នកចូលរលឹកតអំពីនោះទៅ ។

ខ្ញុំបានពោលនូវបុព្វកម្ម ដែលខ្លួនខ្ញុំបានអប់រំហើយ ថ្វាយព្រះពុទ្ធជាម្ចាស់ថា

ខ្ញុំខានបានឃើញព្រះពុទ្ធ មានបុញ្ញលក្ខណៈច្រើន មានវិសុទ្ធិជាបច្ច័យក្នុងកាលមុនអស់កាលយូរហើយ ទើបតែក្នុងថ្ងៃនេះ ខ្ញុំបានឃើញព្រះកាយរបស់ព្រះអង្គ ដ៏គួររមិលមើលរកបុគ្គលប្រៀបពុំបាន ។

ខ្ញុំបានតម្កល់បុណ្យចំពោះព្រះអង្គអស់កាលយូរ កិលេសទាំងឡាយ ខ្ញុំបានឲ្យរីងស្ងួតមិនមានសេសសល់ ដោយការក្សាដ៏ស្អាត បពិត្រមហាមុនី ភ្នែកគឺញាណ មិនមានមន្ទិល ខ្ញុំបានជម្រះហើយអស់កាលយូរ ។

(រឿងមេឃតាបសជាមិត្តរបស់សុមេធបណ្ឌិត)

ខ្ញុំព្រះអង្គប្រកបជាមួយនឹងព្រះអង្គ អស់កាលដ៏យូរ មិនវិនាសក្នុងចន្លោះថ្មីទៀត អស់កាលដ៏យូរ ក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គប្រកបព្រមជាមួយនឹងព្រះអង្គម្តងទៀត បពិត្រព្រះគោតមៈ អំពើទាំងឡាយដែលខ្ញុំបានធ្វើ មិនវិនាសឡើយ ។

កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទឹង ។

ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះធម្មរុចិត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

***គប្បីជ្រាបរឿងក្នុងអបទានទី ៩ នៃវគ្គទី ៤៩ ដូចតទៅ ៖***

បទថា **តទាហំ មាណវោ អាសឹ** (**ក្នុងគ្រានោះខ្ញុំជាមាណព**) មានសេចក្តីថា ***សុមេធបណ្ឌិត***បានទទួលព្យាករណ៍អំពី***ព្រះមានព្រះភាគទីបង្ករ*** ក្នុងកាលណា, ក្នុងកាលនោះ ខ្ញុំជា***ព្រាហ្មណមាណព*** មានឈ្មោះថា **មេឃ** បានបួសជាឥសីជាមួយនឹងសុមេធតាបស ហើយបានសិក្សាក្នុងសិក្ខាបទទាំងឡាយ (តែ) ដោយការច្របូកច្របល់ជាមួយបាបមិត្រណាមួយ ក៏លុះក្នុងអំណាចនៃការត្រិះរិះមិនល្អ ដោយទោសនៃការសេពគប់ខុស (បានធ្វើមាតុឃាតកម្ម) ដោយអំណាចមាតុឃាតកម្មនោះ ក៏បានសោយទុក្ខដោយអណ្តាតភ្លើងជាដើមក្នុងនរក, កាលចុតិចាកអត្តភាពនោះហើយ បានកើតជាមហាមច្ឆាឈ្មោះ ***តិមិង្គល*** ក្នុងសមុទ្រ, ជាអ្នកប្រាថ្នាលេបនាវាដ៏ធំដែលកំពុងទៅក្នុងកណ្តាលសមុទ្រ ។ ពួកពាណិជឃើញ

(រឿងមេឃតាបសជាមិត្តរបស់សុមេធបណ្ឌិត)

ត្រីនោះហើយភ័យខ្លាច ស្រែកនូវសំឡេងថា **អហោ គោតមោ ភគវា** ឱហ្ន! ព្រះគោតមដ៏មានព្រះភាគ ។ លំដាប់នោះ ដោយអំណាចបុ**ព្វវាសនា** មហាមច្ឆាក៏កើតពុ**ទ្ធគារវៈ**, ចុតិចាកអត្តភាពនោះហើយ បានកើតក្នុង**ព្រាហ្មណត្រកូល** ដែលមានទ្រព្យច្រើន ក្នុងនគរសាវត្ថី, ជាអ្នកមានសទ្ធា មានសេចក្តីជ្រះថ្លា បានស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា ហើយបួស និងបានសម្រេចព្រះអរហត្តមួយអន្លើដោយបដិសម្ភិទា លោកទៅទីឧបដ្ឋាន ៣ ដង រាល់ថ្ងៃរលឹក ថ្វាយបង្គំព្រះសាស្តា ។ គ្រានោះ ព្រះមានព្រះភាគត្រាស់នឹងលោកថា **ចិរំ ធម្មរុចិ** ម្នាលធម្មរុចិ អស់កាលដ៏យូរមកហើយ ដូច្នេះ ។

ចប់ ធម្មរុចិត្ថេរាបទាន ។

(សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន ថេរាបទាន បំសុកូលវគ្គ ទី ៤៩ បិដកលេខ ៧៥ ទំព័រ ១៨៧ និង អដ្ឋកថា)

## មហាមច្ឆា

ក្នុងមហាសមុទ្រ មានត្រី ឈ្មោះ **តិមិ** មានប្រវែង ២០០ យោជន៍

ត្រីតិមិង្គល		មានប្រវែង ៣០០ យោជន៍

ត្រីតិមិបិង្គល		មានប្រវែង ៤០០ យោជន៍

ត្រីតិមិរបិង្គល		មានប្រវែង ៥០០ យោជន៍

ត្រីអានន្ទ ត្រីតិមិនន្ទ ត្រីអជ្ឈារោហៈ ត្រីមហាតិមិ មានប្រវែង ១០០០ យោជន៍ ។

(សុមង្គលវិលាសិនី អដ្ឋកថា ទីឃនិកាយ មហាវគ្គ មហានិទានសូត្រ ឧស្សាទនាវណ្ណនា)

ក្នុងមហាសមុទ្រ មាន ត្រី ឈ្មោះ តិមិ មានប្រវែង ២០០ យោជន៍

ត្រីតិមិង្គល		មានប្រវែង ៣០០ យោជន៍

ត្រីតិមិរបិង្គល		មានប្រវែង ៥០០ យោជន៍

ត្រីអានន្ទ ត្រីតិមិនន្ទ ត្រីអជ្ឈារោហៈ ត្រីមហាតិមិ មានប្រវែង ១០០០ យោជន៍ ។

(សារត្ថប្បកាសិនី អដ្ឋកថា សំយុត្តនិកាយ និទានវគ្គ និទានសំយុត្ត ទុក្ខវគ្គ និទានសូត្រ)

## *(រឿងមេឃតាបសជាមិត្តរបស់សុមេធបណ្ឌិត)*

*បានឮតៗមកថា ក្នុងអតីតកាលដ៏យូរលង់ណាស់ទៅហើយ នៅក្នុងមហាសមុទ្រ មានមហាមច្ឆា ៦ ក្បាល ។ ក្នុងបណ្ដាមហាមច្ឆាទាំងឡាយនោះ មច្ឆាទាំងឡាយ ៣ នេះគឺ មច្ឆាឈ្មោះ អានន្ទ ១ តិមិនន្ទ ១ អជ្ឈារោហៈ ១ មានប្រវែង ៥០០ យោជន៍ ។*

*មច្ឆាទាំងឡាយ ៣ នេះគឺ តិមិង្គល ១ តិមិរបិង្គល ១ មហាតិមិរបិង្គល ១ មានប្រវែង ១០០០ យោជន៍ ។*

*សូម្បីមច្ឆាទាំងអស់នោះ ជាសត្វដែលមានថ្ម និងសារាយជាអាហារ ។ ប៉ុន្តែខាងក្រោយមក មច្ឆាខ្លះក៏បរិភោគស៊ីទូវត្រី និងសត្វផ្សេងៗជាអាហារ ។*

*(ជាតកដ្ឋកថា អសីតិនិបាត មហាសុតសោមវណ្ណនា)*

*សូមថ្លែងអំណរគុណយ៉ាងក្រៃលែងចំពោះព្រះអង្គគ្រូ **ធម្មកាមោ មិត្ត សាន** ដែលបានជួយណែនាំឯកសារខ្លះសម្រាប់ធម្មទានដ៏ប្រពៃថ្ងៃថ្វាមួយនេះ ។*

**សព្វទានំ ធម្មទានំ ជិនាតិ**

*ធម្មទានរមែងឈ្នះអស់ទានទាំងពួង*

*ថ្ងៃព្រហស្បតិ៍ ៨ រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤*

*ត្រូវនឹងថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០*

*ថ្ងៃនេះ ជាថ្ងៃសីល*

*ដោយបណ្ឌិត*

**កុល ផេង**